# សេចក្តីជូនដំណឹង

# ស្តីពី

# ការធ្វើបរិវិសកម្មអស់ទាំងស្រុងនៃសញ្ញាបណ្ណចីរភាពអិលអូអិលស៊ីមានបុគ្គលធានា និងការពន្យារពេលបោះផ្សាយលក់ជាសាធារណៈនៃសញ្ញាបណ្ណចីរភាពអិលអូអិលស៊ីមានអាទិភាពខ្ពស់ មិនមានបុគ្គលធានា របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** (“**ក្រុមហ៊ុនបោះផ្សាយ**” ឬ "**គ្រឹះស្ថាន**") សូមជម្រាបជូនសាធារណជន និងភាគីពាក់ព័ន្ធទាំងអស់មេត្តាជ្រាបថា **សញ្ញាបណ្ណចីរភាពអិលអូអិលស៊ីមានបុគ្គលធានា ក្នុងទំហំទឹកប្រាក់ចំនួន ២០ លានដុល្លារអាមេរិក** ត្រូវបានវិនិយោគិនធ្វើបរិវិសកម្មអស់ទាំងស្រុង។ ដំណើរការបោះផ្សាយ និងការប្រកាសលទ្ធផលបរិវិសកម្ម នឹងបន្តប្រព្រឹត្តទៅស្របតាមកាលវិភាគដែលបានជម្រាបជូននាពេលកន្លងមក។

ដោយសញ្ញាបណ្ណចីរភាពមានបុគ្គលធានារបស់គ្រឹះស្ថានត្រូវបានធ្វើបរិវិសកម្មពេញលេញ និងដោយបានពិចារណាលើស្ថានភាពសាច់ប្រាក់ដ៏រឹងមាំ និងតម្រូវការហិរញ្ញប្បទានបច្ចុប្បន្នរបស់គ្រឹះស្ថាន គ្រឹះស្ថានបានទទួលការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ក្នុងការពន្យារពេលកាលបរិច្ឆេទបរិវិសកម្ម និងការបោះផ្សាយលក់ជាសាធារណៈនៃសញ្ញាបណ្ណចីរភាពអិលអូអិលស៊ីមានអាទិភាពខ្ពស់ មិនមានបុគ្គលធានា។

គ្រឹះស្ថានមានបំណងប្រើប្រាស់ថវិកាចំនួន **២០ លានដុល្លារអាមេរិក** ដែលទទួលបានពីការ បោះផ្សាយលក់សញ្ញាបណ្ណចីរភាពអិលអូអិលស៊ីមានបុគ្គលធានាជាមុនសិន សម្រាប់គម្រោងបៃតង និងសង្គម ដែលមានសិទ្ធិស្របតាមក្របខ័ណ្ឌសញ្ញាបណ្ណចីរភាព និងការប្តេជ្ញាចិត្តរបស់គ្រឹះស្ថានលើការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយ ដូចដែលបានជម្រាបជូនវិនិយោគិន។

សញ្ញាបណ្ណចីរភាពអិលអូអិលស៊ីមានអាទិភាពខ្ពស់មិនមានបុគ្គលធានានេះ ត្រូវបានគ្រោងនឹងបោះផ្សាយលក់ឡើងវិញក្នុងទម្រង់ជា**ការបោះផ្សាយលក់ដំណាក់កាលទីពីរ**។ ការពន្យារពេលនេះ នឹងផ្តល់ពេលវេលាបន្ថែមជូនវិនិយោគិនដែលមានបំណងចូលរួម ក្នុងការពិនិត្យមើលព័ត៌មានពាក់ព័ន្ធ ការសម្រេចចិត្តវិនិយោគដោយមានការយល់ដឹងច្បាស់លាស់ និងរៀបចំខ្លួនសម្រាប់ការចូលរួមក្នុងដំណាក់កាលបោះផ្សាយលក់នោះ។ គ្រឹះស្ថាននឹងប្រកាសជូននូវកាលបរិច្ឆេទនៃការបោះផ្សាយលក់ឡើងវិញនាពេលសមស្របខាងមុខ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយកចិត្តទុកដាក់ ការគាំទ្រ និងទំនុកចិត្តជាបន្តបន្ទាប់ពីសំណាក់វិនិយោគិន និងភាគីពាក់ព័ន្ធទាំងអស់។